គណៈកម្មាធិការស្ត្រីកម្ពុជា
Cambodian Committee of Women
(CAMBOW)

ណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ
Cambodian NGO Committee on CEDAW

# សេចក្តីថ្លែងការណ៍រួមរបស់ NGO-CEDAW និង CAMBOW

យើងខ្ញុំជាសមាជិក NGO-CEDAW និង CAMBOW ដែលជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ធ្វើការដើម្បីភាពរីកចម្រើនលើសិទ្ធិរបស់ស្ត្រី សូមអំពាវនាវយ៉ាងទទូចដល់តុលាការរាជធានីភ្នំពេញ សូមមេត្តាលើកលែងនូវការចោទប្រកាន់មនុស្សទាំង ២៣ នាក់ដែលត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី ២ និងទី ៣ ខែ មករា ឆ្នាំ ២០១៤។ បុរសដែលជាជនស្លូតត្រង់ទាំងនេះ គឺជាកូន ជាស្វាមី ជាឪពុក ជាបង ជាប្អូន របស់ស្ត្រី និងកុមារីជាច្រើនដែលកំពុងរងចាំវត្តមានរបស់ពួកគាត់ ដើម្បីផ្តល់នូវភាពកក់ក្តៅដល់ក្រុមគ្រួសារ និងជួយផ្គត់ផ្គង់ដល់ជីវភាពក្រុមគ្រួសារ។

យើងខ្ញុំក៏សូមអំពាវនាវយ៉ាងទទូចផងដែរដល់តុលាការ សូមមេត្តាដោះលែងអ្នកនៅបន្តជាប់ឃុំឃាំងទាំង ២១ នាក់ ដែលត្រូវបានចាប់ខ្លួនដោយសារតែកិច្ចប្រឹងប្រែងរបស់ពួកគាត់ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីប្រាក់ឈ្នួល និងទាមទារឲ្យមានការដំឡើងប្រាក់ឈ្នួលគ្រប់គ្រាន់នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ដែលយ៉ាងតិចណាស់ឲ្យបានដល់កម្រិតមួយដែលអាចរស់នៅសមរម្យបាន ដែលការទាមទារនេះក៏ស្របទៅតាមការវាយតម្លៃរបស់រដ្ឋាភិបាលទៅលើប្រាក់ឈ្នួលសមរម្យនោះដែរ។

បើទោះជាតុលាការបានអនុញ្ញាតិឱ្យមនុស្ស ២ នាក់ បានស្ថិតនៅក្រៅឃុំបណ្តោះអាសន្នក៏ដោយ ក៏មនុស្សទាំង ២១ នាក់ទៀត នៅតែបន្តឃុំខ្លួននៅឡើយ ដែលកាលពីមុនពួកគាត់ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលកែប្រែ ម ៣ បច្ចុប្បន្ននេះត្រូវបានឃុំខ្លួននៅមណ្ឌលកែប្រែ ម ១ ដើម្បីរងចាំសវនាការនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

ដោយឡែក យើងខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខភាពរបស់លោក សុគន្ធ សម្បត្តិពិសិដ្ឋ និងលោក វន់ ពៅ ដែលសភាពជម្ងឺរបស់លោកទាំងពីរកាន់តែធ្ងន់ធ្ងរឡើងៗ និងចាំបាច់ត្រូវទទួលការព្យាបាលជាបន្ទាន់។ ក្នុងអំឡុងពេលចាប់ខ្លួនរបស់លោកទាំងពីរ កាលពីថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៤ ពួកគាត់ត្រូវបានវាយដំយ៉ាងខ្លាំងពីសំណាក់អាជ្ញាធរ។

លោក សម្បត្តិពិសិទ្ធិ បានរងរបួសយ៉ាងធ្ងន់ធ្ងរ និងបាក់ដៃ ដែលត្រូវការការវះកាត់ជាបន្ទាន់។ ចំណែកឯលោក វន់ ពៅ ដែលជាសមាជិកសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល មានឈ្មោះ

ថា NGO-CEDAW និង CAMBOW ដោយនៅមុនការចាប់ខ្លួន រូបលោកបានទទួលការវះកាត់ព្យាបាលជម្ងឺមហារីកតម្រងនោម។ បច្ចុប្បន្ននេះ សុខភាពរបស់លោកមានសភាពទន់ខ្សោយ និងអាចប្រឈមទៅនឹងការកើតឡើងវិញនូវជម្ងឺមហារីកនេះ។

ការមិនបានយកចិត្តទុកដាក់ដ៏ហ្មត់ចត់ពីសំណាក់តុលាការ និងពីសំណាក់មន្ត្រីពន្ធនាគារ និងការដែលមិនបានអនុញ្ញាត និងផ្តល់នូវការព្យាបាលក៏ត្រឹមត្រូវដល់អ្នកជាប់ឃុំឃាំងទាំងពីរដែលរងរបួសធ្ងន់ធ្ងរនោះ គឺបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការរំលោភសិទ្ធិជាមូលដ្ឋានរបស់ពួកគាត់ និងរំលោភទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជារំលោភទៅលើច្បាប់អន្តរជាតិដទៃទៀតដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមអំពាវនាវយ៉ាងទទូចដល់អាជ្ញាធរ សូមមេត្តាស្វែងរក និងចាប់ខ្លួនជនល្មើសពិតប្រាកដដែលបានបាញ់គ្រាប់ពិត និងបានបង្កឲ្យមានមនុស្សស្លាប់យ៉ាងតិច ៤ នាក់ នៅខណៈដែលកងកម្លាំងសន្តិសុខបានបង្ក្រាបដោយហិង្សាទៅលើក្រុមបាតុករ កាលពីថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៤។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:

- កញ្ញា អ៊ូ ទេពផល្លីន ទូរស័ព្ទ: ០១១ ៩៨៩ ៨៨៣/០៩៨ ៩៨៩ ៨៨៣
  អ៊ីម៉ែល: phallin@cfswf.org
- លោក ហេង សំអន ទូរស័ព្ទ: ០១៥ ៧៧០ ១២០
  អ៊ីម៉ែល: orn_idea@yahoo.com
- អ្នកស្រី ជឹម ចាន់នាង ទូរស័ព្ទ: ០១២ ៦៦៨ ៨៥៣
  អ៊ីម៉ែល: ngocedaw.pnh@gmail.com